**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពត៌មាន**
**MINISTRY OF INFORMATION**

លេខ ៤០១៥/០២ ព.ម ក្រប-ក

រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពីការរៀបចំនិងការគ្រប់គ្រងកិច្ចការអាស៊ាន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២-នស៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦-១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ-បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ២១-អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទាំង ៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ
- យោងតាមតម្រូវការចាំបាច់ក្នុងការរៀបចំ និងការគ្រប់គ្រងកិច្ចការអាស៊ានឡើងវិញ

## សំរេច

**ប្រការ ១:** ដកការិយាល័យអាស៊ាន ពីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មកដាក់ក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ២:** តែងតាំង ឯកឧត្តម **សារ៉ុន ជន** អនុរដ្ឋលេខាធិការ ជាប្រធានគណៈកម្មាធិការជាតិវប្បធម៌ និងពត៌មាន អាស៊ាន-កម្ពុជា និង ត្រូវទទួលបន្ទុកគ្រប់គ្រងការិយាល័យអាស៊ានដោយផ្ទាល់ ។

**ប្រការ ៣:** តែងតាំង លោក **ហ៊ីម សួន** អគ្គនាយករងនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ជាប្រធានអនុគណៈកម្មាធិការពត៌មាន នៃគណៈកម្មាធិការជាតិវប្បធម៌ និងពត៌មានអាស៊ាន-កម្ពុជា ។

Downloaded from http://www.khmerlaws.com

**ប្រការ ៤:** តែងតាំង លោក **ចាស់ សំអាត** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវប្បធម៌ និងពត៌មាន អាស៊ាន-កម្ពុជា ។

**ប្រការ ៥:** ឯកឧត្តមអគ្គនាយកគ្រប់អគ្គនាយកដ្ឋានចំណុះ ប្រធាននាយកដ្ឋានបុគ្គលិក នាយកខុទ្ទកាល័យ និងសាមីខ្លួន ត្រូវអនុវត្ត តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ រាល់បទបញ្ញត្តិទាំងឡាយដែលផ្ទុយពីប្រកាស នេះ ត្រូវទុកជានិរាករណ៍ ។

**រដ្ឋមន្ត្រី**

ឆិ. ឡាយស្រ៊ុខ

**<u>ចំលងជូន</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួង មុខងារសាធារណៈ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ "ដើម្បីជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ

Downloaded from http://www.khmerlaws.com